*រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦*

# សេចក្តីប្រកាសព័ត៌មាន

ក្នុងរយៈពេលពេញមួយថ្ងៃនេះ, ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦, នៃពិធីប្រកាសដាក់ឱ្យអនុវត្ត ដំណាក់កាលទី ៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចប្រជុំត្រួតពិនិត្យវាយតម្លៃ វឌ្ឍនភាពប្រចាំឆ្នាំ ២០១៥ ដែលរៀបចំដោយគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញ វត្ថុសាធារណៈ (Public Financial Management Reform Program Steering Committee), កិច្ច ប្រជុំបានពិនិត្យ និងពិភាក្សាលើវឌ្ឍនភាព និងបញ្ហាប្រឈម ក្នុងការអនុវត្តកម្មវិធីកែទម្រង់ក្នុងរយៈកាល កន្លងមក ដើម្បីកំណត់គោលដៅសម្រាប់ជំហានបន្ទាប់ ។

ជាមោទនៈភាព, នៅក្នុងរយៈពេលជាង ១០ ឆ្នាំនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ, តាមរយៈការដាក់ឲ្យអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងដំណាក់កាលទី ១ កាលពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០០៨, រាជរដ្ឋាភិបាលបានកសាង និងសម្រេចបាន ជាសារវន្តនូវមូលដ្ឋាននៃ “**ភាពជឿទុកចិត្តនៃថវិកា**” តាមរយៈការផ្តល់អាទិភាពបន្ទាន់លើការងារពង្រឹង ការប្រមូលចំណូល និងការគ្រប់គ្រងចំណូល, ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និងការកែលម្អនីតិវិធីនៃ ការអនុវត្តថវិកា ។ ឈរលើមូលដ្ឋានខាងលើ, រាជរដ្ឋាភិបាលបានបន្តដាក់ឲ្យអនុវត្តដំណាក់កាលទី ២ ពី ឆ្នាំ ២០០៩ ដល់ឆ្នាំ២០១៥, ដោយសម្រេចឲ្យបាននូវការបង្កើន “**គណនេយ្យភាពហិរញ្ញវត្ថុ**” ដោយផ្តោត ជាសំខាន់ក្នុងការរៀបចំលម្អ ព្រមទាំងការកត់ត្រា និងធ្វើរបាយការណ៍គណនេយ្យ និងហិរញ្ញវត្ថុឲ្យ កាន់តែត្រឹមត្រូវ, ច្បាស់លាស់, សុក្រឹត្យ និងទាន់ពេលវេលា ស្របតាមស្តង់ដារអន្តរជាតិ ។

ថ្ងៃនេះ, គឺជាការបោះជំហានដ៏សំខាន់ថ្មីមួយទៀត គឺការដាក់ឲ្យអនុវត្តដំណាក់កាលទី ៣ “**ការ ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**” គឺជាជំហានកែទម្រង់មួយថ្មីទៀតដោយធ្វើការផ្លាស់ប្តូរមួយ ចំណែកម្តងៗ នៃប្រព័ន្ធថវិកាបច្ចុប្បន្ន តាមប្រកាសដាក់ឲ្យអនុវត្តមាតិកាថវិកាថ្មី, ស្តង់ដារគណនេយ្យ និងប្លង់គណនេយ្យថ្មី, អង្គភាពថវិកា និងនីតិវិធីថ្មីនៃការអនុវត្តថវិកា រួមជាមួយនឹងប្រព័ន្ធព័ត៌មានវិទ្យា សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជំហានទី ១ ព្រមទាំងចាប់ផ្តើមពង្រឹង និងពង្រីកប្រព័ន្ធ “**ថវិកា កម្មវិធី**” ពេញលេញ, ជាជំហានៗ, ទៅក្នុងចំណោមក្រសួង-ស្ថាប័នរដ្ឋ គ្រប់ថ្នាក់, ទាំងថ្នាក់ជាតិ និងថ្នាក់ ក្រោមជាតិ, ដោយចាប់ផ្តើមពីឆ្នាំ ២០១៥ រហូតដល់ឆ្នាំ ២០១៨ ស្របតាម “**ទស្សនទានស្តីពីទិសដៅយុទ្ធ សាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ២០១៣-២០២០**” ក្នុងគោលដៅបោះជំហានឆ្ពោះទៅកាន់ការប្រែ ប្រព័ន្ធថវិកាទាំងស្រុងពី “**ប្រព័ន្ធថវិកាផ្តោតលើធាតុចូល និងមជ្ឈការ ទៅជាប្រព័ន្ធថវិកាផ្តោតលើលទ្ធ ផល ឬធាតុចេញ និងវិមជ្ឈការ**” ។

ដូចដែល សម្តេចតេជោនាយករដ្ឋមន្ត្រី បានគូសបញ្ជាក់ថា “ថវិកា គឺជា ឧបករណ៍នៃគោលនយោបាយ”, រាជរដ្ឋាភិបាលត្រូវមានគោលនយោបាយ និងថវិកាសម្រាប់អនុវត្តន៍ច្បាស់លាស់ ដើម្បីអភិវឌ្ឍន៍ ហើយ ក្រសួង-ស្ថាប័នទាំងអស់ ត្រូវធ្វើការកែលម្អ និងពង្រឹងថែមទៀត ក្នុងការកំណត់គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់ខ្លួន ដើម្បីធានាសង្គតិភាព, ភាពត្រឹមត្រូវ, ច្បាស់លាស់, និងភាពអាចវាស់វែងបាននូវលទ្ធផល ឬ សមិទ្ធកម្មបាន ព្រមទាំងហ៊ានធ្វើ-ហ៊ានទទួលខុសត្រូវ ។ ជាមួយគ្នានេះ ក្រសួង ស្ថាប័នទាំងអស់ ត្រូវរៀបចំប្រែក្លាយការបណ្តុះបណ្តាលសមត្ថភាព និងក្របខ័ណ្ឌយុទ្ធសាស្ត្រគតិយុត្តសម្រាប់អនុវត្តប្រព័ន្ធថវិកាថ្មី គឺ “**ថវិកាកម្មវិធី**” ។

ក្នុងន័យនេះ, ឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានគូសរំលេចថា ដើម្បីធានាបាននូវសង្គតិភាព និងលើកកម្ពស់ប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ, ចាំបាច់ត្រូវពិនិត្យ និងកែលម្អបន្ថែម, ក្នុងពេលដំណាលគ្នា, ទាំងការរៀបចំ និងការអនុវត្តថវិកា, ទាំងរចនាសម្ព័ន្ធស្ថាប័នគ្រប់គ្រង, សំដៅធានានូវការបន្សុីគ្នា និងការឆ្លងឆ្លើយគ្នារវាងថវិកាជាមួយនឹងគោលបំណងគោលនយោបាយ ព្រមទាំងរចនាសម្ព័ន្ធស្ថាប័ន ដែលជាយន្តការអនុវត្តគោលនយោបាយ ។ ជាមួយគ្នានេះ, ការអនុវត្តត្រូវគួបផ្សំគ្នារវាងអភិក្រម “**ពីលើចុះក្រោម**” និង “**ពីក្រោមឡើងលើ**” ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអ្នកដឹកនាំរៀបចំ “**ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច**” និង “**ក្របខ័ណ្ឌថវិការយៈពេលមធ្យម**” ជាដើម ហើយក្រសួង-ស្ថាប័នជំនាញត្រូវមាន“**ផែនការយុទ្ធសាស្ត្រថវិកា**” និង “**គម្រោងថវិកាកម្មវិធីប្រចាំឆ្នាំ**” ជាដើម ។

ជារួម, មកដល់បច្ចុប្បន្ននេះ, វឌ្ឍនភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានទទួលបានការគាំទ្រពីដៃគូអភិវឌ្ឍន៍ ដោយឯកឧត្តម George Edgar អគ្គរដ្ឋទូត និងជាប្រធានសហភាពអ៊ឺរ៉ុបប្រចាំនៅកម្ពុជា និងជាតំណាងដៃគូអភិវឌ្ឍន៍បានវាយតម្លៃខ្ពស់ និងគូសបញ្ជាក់ថា ដៃគូអភិវឌ្ឍន៍ត្រៀមខ្លួនជាស្រេច ដើម្បីអមដំណើររាជរដ្ឋាភិបាលក្នុងការបន្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យស៊ីជម្រៅនិងខ្លាំងក្លាបន្ថែមទៀត ។ ជាពិសេស សហភាពអ៊ឺរ៉ុប នឹងផ្តល់ការគាំទ្រចាប់ពីឆ្នាំ ២០១៦ នេះ តាមរយៈថវិកាគាំទ្រ (Budget Support Modality) ដោយប្រើប្រាស់ប្រព័ន្ធរបស់រាជរដ្ឋាភិបាលផ្ទាល់ ។

<u>**កំណត់សម្គាល់**</u>÷

សុន្ទរកថា និងឯកសារទាំងអស់អាចទាញយកបានពីគេហទំព័ររបស់÷

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ: www.pfm.gov.kh, និង
- អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ: www.mef.gov.kh ។